# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៧១..សសរ.

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការបច្ចេកទេសសម្រាប់គម្រោងសាងសង់ ពហុកីឡាដ្ឋានជាតិមរតកតេជោ ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណង ពីសាធារណរដ្ឋប្រជាមានិតចិន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧៤.អនក្រ.បក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍
- សេចក្តីសម្រេចលេខ ១៦៣.សសរ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសំណើប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា។

## សម្រេច

**ប្រការ ១.**

ត្រូវបានបង្កើតគណៈកម្មការបច្ចេកទេសសម្រាប់គម្រោងសាងសង់ **"ពហុកីឡាដ្ឋានជាតិមរតកតេជោ"** ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងពីសាធារណរដ្ឋប្រជាមានិតចិន ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. **ឯកឧត្តម ថោង ខុន** | ប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | ប្រធាន |
| ២. **ឯកឧត្តម ប៉ែន សុផល** | រដ្ឋលេខាធិការក្រសួងដែនដី រូបនីយកម្ម និងសំណង់ | សមាជិក |
| ៣. **ឯកឧត្តម ហែម វណ្ណឌី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤. **ឯកឧត្តម លូ រ៉ាមីន** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៥. **ឯកឧត្តម ឆា ដុប** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៦. **ឯកឧត្តម អ៊ឹក សិទ្ធិជាតិ** | អគ្គនាយកកីឡានៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៧. **ឯកឧត្តម អឿង អូនលី** | អភិបាលរងរាជធានីភ្នំពេញ | សមាជិក |

គណៈកម្មការបច្ចេកទេសនេះមានភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ និងសម្របសម្រួលជាមួយភាគីចិនពាក់ព័ន្ធលើការងារសិក្សាសមិទ្ធិលទ្ធភាពការរៀបចំគម្រោង និងការអនុវត្តគម្រោង។
- ពិនិត្យ សម្រេចលើលក្ខណៈបច្ចេកទេស តម្លៃ និងការអនុវត្តនីតិវិធីនានារបស់គម្រោង រួមទាំងការចុះហត្ថលេខាលើកិច្ចសន្យាពាក់ព័ន្ធនានារបស់គម្រោង។
- ត្រូវរាយការណ៍ជាប្រចាំអំពីលទ្ធផលនៃការងារអនុវត្តគម្រោងជូនអង្គភាព ក្រសួង-ស្ថាប័នតាមភាពចាំបាច់។ ក្នុងករណីត្រូវចាត់វិធានការលើសពីសមត្ថកិច្ចរបស់ខ្លួន គណៈកម្មការអាចសហការ ឬស្នើអោយមានកិច្ចសហការពីក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ តាមតម្រូវការ ចាំបាច់ជាក់ស្តែង។
- សហការជាមួយក្រុមជំនាញបច្ចេកទេសសាធារណរដ្ឋប្រជាមានិតចិន រាល់នីតិវិធីនៃដំណើរការការងារសាងសង់។

**ប្រការ២.**

ត្រូវបានបង្កើតលេខាធិការដ្ឋានរបស់គណៈកម្មការបច្ចេកទេសនៃគម្រោងសាងសង់ **"ពហុកីឡាដ្ឋានជាតិមរតកតេជោ"** ដែលមានសមាសភាព និងភារកិច្ចដូចខាងក្រោម៖

| | | |
|---|---|---|
| ១. **ឯកឧត្តម ជា ប៊ុនា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ និងជាប្រធានផ្នែកហេដ្ឋារចនាសម្ព័ន្ធកីឡាមូលនិធិកីឡានៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | ប្រធាន |
| ២. **ឯកឧត្តម ម៉ាត់ ចំរើន** | អគ្គលេខាធិការគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | អនុប្រធាន |
| ៣. **លោក ម៉ា ហេងជាឌុង** | អនុប្រធានផ្នែកហេដ្ឋារចនាសម្ព័ន្ធកីឡាមូលនិធិកីឡានៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | សមាជិក |
| ៤. **លោក មាន្ស សណ្ណាម់** | អគ្គនាយករងទេសចរណ៍ | សមាជិក |

លេខាធិការដ្ឋាននេះមានភារកិច្ច ដូចខាងក្រោម៖

- ជាជំនួយដល់គណៈកម្មការបច្ចេកទេសក្នុងការសម្របសម្រួលការងារជាប្រចាំជាមួយភាគីចិនពាក់ព័ន្ធលើការងារសិក្សាសមិទ្ធិលទ្ធភាព ការរៀបចំគម្រោង និងការអនុវត្តគម្រោង។
- សហការជាមួយភាគីចិនក្នុងការពិនិត្យលើលក្ខណៈបច្ចេកទេស តម្លៃ និងការអនុវត្តនីតិវិធីនានារបស់គម្រោង ដើម្បីរាយការណ៍ជូនប្រធានគណៈកម្មការបច្ចេកទេសពិនិត្យសម្រេច។
- សហការជាមួយភាគីចិន ក្នុងការជ្រើសរើស និងត្រួតពិនិត្យប្លង់ រចនាស្ថាបត្យកម្មនៅសាធារណរដ្ឋប្រជាមានិតចិន ។
- សហការជាមួយក្រុមជំនាញបច្ចេកទេសសាធារណរដ្ឋប្រជាមានិតចិន រាល់នីតិវិធីនៃដំណើរការការងារសាងសង់ និងត្រួតពិនិត្យការងារសាងសង់។
- រាយការណ៍ជាប្រចាំអំពីលទ្ធផលនៃការងារអនុវត្តគម្រោងជូនប្រធានគណៈកម្មការបច្ចេកទេសតាមការចាំបាច់។

**ប្រការ៣.**

គណៈកម្មការនេះមានសិទ្ធិជ្រើសរើសបន្ថែមមន្ត្រីគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា អោយបំពេញការងារតាមតម្រូវការចាំបាច់។

**ប្រការ៤.**

គណៈកម្មការបច្ចេកទេសនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ដើម្បីដំណើរការងាររបស់ខ្លួន តាមការចាំបាច់។

សមាជិកគណៈកម្មការបច្ចេកទេស និងប្រធាន អនុប្រធាន សមាជិកលេខាធិការដ្ឋាន ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ។

**ប្រការ៥.**

គណៈកម្មការបច្ចេកទេសនេះ នឹងត្រូវរំសាយក្រោយចប់ភារកិច្ច។

**ប្រការ៦.**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងពាក់ព័ន្ធ ប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងសាម៉ីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**